ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ: ០៦៦/២១.សណណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ជូនប្រជាពលរដ្ឋមានអាយុពី ១៨ ឆ្នាំឡើងទៅ កុមារ និងយុវវ័យ អាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលខកខាន មិនបានមកទទួលវ៉ាក់សាំង នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

**រដ្ឋបាលរាជធានីភ្នំពេញ** សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋ មាតាបិតា អាណាព្យាបាល និងសាធារណជនទាំងអស់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ មេត្តាជ្រាបថា ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់កុមារ និងយុវវ័យ អាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋមានអាយុពី ១៨ ឆ្នាំឡើងទៅ នាពេលកន្លងមក **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំង** ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ សម្រេចបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់កុមារ និងយុវវ័យ ប្រមាណជាង ២០ម៉ឺននាក់រួចមកហើយ ខណៈពេលដែលការអនុវត្តការងារចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋមានអាយុពី ១៨ ឆ្នាំឡើងទៅ សម្រេចបានជិត ១លាន ៧សែននាក់ ស្ទើរគ្រប់តាមផែនការកំណត់។ លទ្ធផលគួរជាទីមោទនៈនេះ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ មាតាបិតា និងអាណាព្យាបាល ក្នុងការមកទទួល និងនាំបុត្រធីតា សាច់ញាតិរបស់ខ្លួនទៅទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅទប់ស្កាត់ និងឈានទៅកាត់ផ្តាច់ចរន្តចម្លងជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា(Delta)។

ទន្ទឹមនេះ **រដ្ឋបាលរាជធានីភ្នំពេញ** បានសង្កេតឃើញថាមានបងប្អូនប្រជាពលរដ្ឋ កុមារ និងយុវវ័យមួយចំនួនខកខានមិនទាន់បានអញ្ជើញទៅទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩នៅឡើយ ដោយមូលហេតុផ្សេងៗ ដូចជា មានបញ្ហាសុខភាព ជាប់អនុវត្តវិធានចត្តាឡីស័ក ទើបគ្រប់អាយុកំណត់ ឬជាប់ធុរៈផ្សេងៗជាអាទិ៍។ ក្នុងន័យនេះ និងដើម្បីបន្តអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យសម្រេចបានតាមលទ្ធផលគ្រោងទុក ក៏ដូចជាពង្រីកវិសាលភាពនៃការគ្របដណ្តប់វ៉ាក់សាំងជូនដល់ប្រជាពលរដ្ឋទាំងអស់ សំដៅបង្កើនភាពស៊ាំក្នុងសហគមន៍ឱ្យកាន់តែរឹងមាំនោះ **អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩** ក្នុងក្របខណ្ឌទូទាំងរាជធានីភ្នំពេញ សម្រេចបន្តការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ជូនដល់កុមារ និងយុវវ័យ ដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និងបន្តការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ និងដូសទី២ ជូនប្រជាពលរដ្ឋអាយុពី ១៨ឆ្នាំឡើងទៅ នៅតាមមន្ទីរពេទ្យបង្អែកចំនួន ០៨ ទីតាំង ដូចមានអាសយដ្ឋានខាងក្រោម៖

| ល.រ | ឈ្មោះមន្ទីរពេទ្យបង្អែក | អាសយដ្ឋាន |
|---|---|---|
| ១ | មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | អគារឡូត៍ទី២ ផ្លូវលេខ ១៣៤ កែងនឹងផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា |
| ២ | មន្ទីរពេទ្យបង្អែកចតុមុខ | អគារលេខ២១១៨ ផ្លូវជាតិលេខ៥ ភូមិ១៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ |

| | | |
|---|---|---|
| ៣ | មន្ទីរពេទ្យបង្អែកដង្កោ | ផ្លូវលេខ២១៧ ភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ |
| ៤ | មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ | ដីឡូត៍លេខ ៣២៨ ផ្លូវសែនសុខ៥ ភូមិសែនសុខ៥ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ |
| ៥ | មន្ទីរពេទ្យបង្អែកច្បារអំពៅ | អគារលេខ២៤ ផ្លូវ៣៦១កែងផ្លូវ៦៣៨ ភូមិដើមម៉ាក់ភ្លឿ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ |
| ៦ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | អគារលេខ៧ ផ្លូវលេខ៥៦K ភូមិតាងួន២ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ |
| ៧ | មន្ទីរពេទ្យបង្អែកព្រែកព្នៅ | ភូមិពោធិមង្គល សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ |
| ៨ | មន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ | ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ |

រដ្ឋបាលរាជធានីភ្នំពេញ សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋដែលមានអាយុពី ១៨ឆ្នាំឡើង អញ្ជើញទៅទទួលចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ និងដូសទី២ និងសូមមាតាបិតា និងអាណាព្យាបាលទាំងអស់នៅរាជធានីភ្នំពេញនាំបុត្រធីតា និងសាច់ញាតិរបស់ខ្លួនដែលមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ទៅទទួលវ៉ាក់សាំងដោយឥតគិតថ្លៃ នៅតាមទីតាំងមន្ទីរពេទ្យបង្អែកដែលនៅជិតលំនៅឋានរបស់ខ្លួន ដូចបានជម្រាបជូនខាងលើ កុំបីខាន នៅរៀងរាល់ម៉ោង០៨:០០ព្រឹក ដល់ម៉ោង ១៧:០០នាទីរសៀល ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់មានការជូនដំណឹងជាថ្មី។

យ៉ាងណាមិញ រដ្ឋបាលរាជធានីភ្នំពេញ សូមក្រើនរំលឹកដល់សាធារណជន មាតាបិតា និងអាណាព្យាបាល ដែលត្រូវមកចាក់វ៉ាក់សាំង ឬនាំបុត្រធីតា និងសាច់ញាតិ ទៅទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវប្រកាន់ភ្ជាប់ឱ្យបាននូវការរក្សាគម្លាតសុវត្ថិភាពបុគ្គល-សង្គម ពាក់ម៉ាសឱ្យបានត្រឹមត្រូវ ឈរតម្រង់ជួរ ចៀសវាងការឈរប្រជ្រៀតគ្នាកៀកគ្នា ហើយត្រូវប្រកាន់ភ្ជាប់ឱ្យបានជាដាច់ខាតនូវវិធានការ "៣ ការពារ និង ៣ កុំ" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ មាតាបិតា និងអាណាព្យាបាល ព្រមទាំងសាធារណជនទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ....ពុធ ២ រោច.....ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី..២៥.....ខែសីហា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ.វ.ក-១៩

  *«ដើម្បីគោរពជូនជ្រាប»*
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ

  *«ដើម្បីអនុវត្ត»*
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

  *«ដើម្បីបន្តផ្សព្វផ្សាយ»*
- ឯកសារ-កាលប្បវត្តិ